CAMBODIA RICE FEDERATION

# ព្រឹត្តិបត្រព័ត៌មានប្រចាំសប្តាហ៍
# WEEKLY BULLETIN

CRF 2020/021 (ថ្ងៃទី២២ ដល់ ២៨ ខែមិថុនា ឆ្នាំ២០២០)

CRF 2020/021 (22 to 28 June 2020)

## សង្ខេបព័ត៌មានសំខាន់ៗអំពីវិស័យស្រូវអង្ករប្រចាំសប្តាហ៍ (Rice News Briefing)

## ក្នុងប្រទេស (In Cambodia)



### កូវីដ១៩ចាប់ផ្តើមប៉ះពាល់ដល់ការធ្វើកសិកម្មនៅកម្ពុជា
### (COVID-19 begins to exact toll on Cambodian farming)

*Medical Express: 23 June 2020*

While Cambodia has been less affected by the health impacts of COVID-19, there are fears that smallholder farms will be hit hard during the wet season that runs from June to September as the fallout from restrictions and lockdown measures takes hold. Agriculture is vital for the Cambodian economy as it employs about 3 million workers, with the rice sector employing a significant majority being the country's main crop and the most important export commodity, according to the World Bank. (Read more)



### សម្តេចតេជោ ហ៊ុន សែន៖ កម្ពុជាកំពុងជំរុញវិស័យកសិកម្ម ខណៈការនាំចេញអង្ករមានការកើនឡើង និងអះអាងថា កម្ពុជាគ្មានបញ្ហាអសន្តិសុខស្បៀងនោះទេ
### (PM: Cambodia is boosting agriculture as rice exports rise and claims that Cambodia has no food insecurity)

*Fresh News: 24 June 2020*

(ភ្នំពេញ)៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០នេះ បានគូសបញ្ជាក់ថា ប្រទេសកម្ពុជា កំពុងតែជំរុញវិស័យកសិកម្ម ខណៈដែលការនាំចេញអង្ករ មានកើនឡើងគួរឲ្យកត់សម្គាល់ និងអះអាងថា បើទោះបីកម្ពុជាយ៉ាងម្តេចក៏ដោយ កម្ពុជាគ្មានបញ្ហាអសន្តិសុខស្បៀងនោះទេ។ (Read more)



### រដ្ឋាភិបាលផ្តល់ថវិកា១០០លានដុល្លារទៅតាមជនបទដើម្បីពង្រីកប្រព័ន្ធធារាសាស្ត្រ
### (The government allocates USD 100 million to countryside to expand irrigation)

*VOD : 25 June 2020*

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា រដ្ឋាភិបាលគ្រោងបង្កើនការទម្លាក់ថវិកាជាង ១០០លានដុល្លារទៅជនបទ ដើម្បីជួយស្តារជីវភាពប្រជាពលរដ្ឋកម្ពុជាឡើងវិញ ខណៈដែលកម្ពុជាកំពុងរងប៉ះផលពាល់ដោយសារវិបត្តិសុខភាពសកលដែលបង្កដោយវីរុសកូរ៉ូណា។ ក្នុងពិធីប្រកាសអនុវត្តន៍កម្មវិធីផ្តល់សាច់ប្រាក់ជូនប្រជាពលរដ្ឋ មានជីវភាពក្រីក្រ និងងាយរងគ្រោះដោយសារជំងឺកូវីដ១៩ នៅថ្ងៃនេះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងថា ការទម្លាក់ថវិកាទំហំដល់ទៅ ១០០លានដុល្លារទៅកាន់តំបន់.... (Read more)



### កសិករខេត្តព្រះវិហារជាផ្នែកសំខាន់ ធ្វើឲ្យអង្ករកម្ពុជាល្បីលើឆាកអន្តរជាតិ
### (Preah Vihear's farmers are the main factor boosting Cambodian rice's fame at the international stage)

*RFI: 26 June 2020*

អង្ករក្រអូប សរីរាង្គ របស់កម្ពុជាដែលមានឈ្មោះល្បីលើទីផ្សារអន្តរភាគច្រើន ដាំដុះនៅខេត្តព្រះវិហារ។ ប្រជាកសិករនៅខេត្តព្រះវិហារបានគ្នាដាំស្រូវសរីរាង្គ តាំងពីឆ្នាំ២០១៣មកម្លេះ ស្រូវសរីរាង្គ ដែលមានទីផ្សារល្អបានលើកកម្ពស់ជីវភាពប្រជាកសិករឲ្យប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ជោគជ័យរបស់កសិករខេត្តព្រះវិហារបានជំរុញឲ្យកសិករតំបន់ផ្សេងទៀតធ្វើការដាំដុះមិនប្រើជីគីមីដែរ។ (Read more)



### ការផ្លាស់ប្តូររបស់ប្រទេសកម្ពុជាពីអសន្តិសុខស្បៀងទៅជាប្រទេសនាំចេញអង្ករ
### (Cambodia's transformation from a food insecurity to a Rice-exporting nation)

*Khmer Times: 28 June 2020*

Prime Minister Hun Sen said Cambodia is aggressively promoting its agricultural sector, particularly the exports of rice. He added that Cambodia will not experience food insecurity like in the past. The statement was made at the official launch of the "Cash Transfer Program for Poor and Vulnerable Households during Covid-19″ on 24 June 2020, at the Peace Palace, Phnom Penh. "We are boosting the agricultural sector this year. With Covid-19, we expected less export, (Read more)

## អន្តរជាតិ (International)

ថៃ (Thailand)

### ថៃនឹងចាប់ផ្តើមដាំដុះស្រូវប្រភេទថ្មី ដើម្បីផ្តល់ផលប្រយោជន៍ដល់ការនាំចេញ
### (Thailand to farm new rice variety seeking export advantages)

*Thailand News: 22 June 2020*



BANGKOK(NNT) - Farmers in Thailand will start cultivating the first lot of the Kor Khor 79 rice variety this year, aiming to introduce the new soft rice variety to the export market, especially in Asia. The Thai Rice Exporters Association (TREA) says the Kor Khor 79 rice variety will initially be farmed on 8 square kilometers of land, in areas served by the irrigation networks, which should produce 2,500 tons at harvest. (Read more)

ឥណ្ឌូនេស៊ី (Indonesia)

### ឥណ្ឌូនេស៊ីព្យាករណ៍ឃើញពីទិន្នផលស្រូវខ្ពស់នៅឆ្នាំ២០២១
### (Indonesia sees higher rice output in 2021, lower corn

*Reuters: 22 June 2020*

JAKARTA, June 22 (Reuters) - Indonesia's Agriculture Ministry data presented at the parliament on Monday: * Indonesia is targetting 63.5 million tonnes output of unhusked rice in 2021, up from this year's target of 59.15 million tonnes. * Indonesia is targetting 26 million tonnes output of corn next year, down from a 2020 corn production target of 30.35 million tonnes.

ថៃ (Thailand)

### ក្រុមប្រឹក្សាយោបល់អំពីការផ្តោតសំខាន់លើតម្លៃស្រូវអង្ករ និងគ្រាប់ពូជ
### (Panel to focus on marketing rice, seeds)

*Bangkok Post: 23 June 2020*

The government looks set to promote seven rice products and seed development as part of a marketing-led production strategy for 2020-2024.

According to Commerce Minister Jurin Laksanawisit, who yesterday chaired the first meeting of a panel tasked with handling the Thai rice strategy, the five-year strategic plan will focus mainly on Thai hom mali rice, Thai fragrant rice, soft-textured white rice, hard-textured white rice, parboiled rice, glutinous rice and speciality quality rice. (Read more)

ឥណ្ឌូនេស៊ី (Indonesia)

### ទីភ្នាក់ងារលទ្ធកម្មចំណីអាហារ នៅឥណ្ឌូនេស៊ី (Bulog) រំពឹងថានឹងមិនមានការនាំចូលអង្ករទេឆ្នាំនេះ
### (Indonesia's Bulog expects no rice imports this year)

*Reuters: 19 June 2020*

JAKARTA, June 23 (Reuters) - Indonesia food procurement agency Bulog currently has 1.4 million tonnes of rice and does not expect a need to import the grain this year, its chief executive said on Tuesday.

Bulog had to double the volume of rice released to the market in recent months in an effort to blunt a price spike caused by demand from social assistance programmes during the country's coronavirus outbreak. (Read more)

វៀតណាម (Vietnam)

### តម្លៃនាំចេញអង្កររបស់វៀតណាម ស្ថិតក្នុងកម្រិតទាបបំផុតក្នុងរយៈពេល ២ខែកន្លងមកនេះ
### (Vietnam's rice export price stands at lowest level over past two months)

*Viet Nam News: 23 June 2020*



HÀ NỘI — Higher rice supplies in the domestic market has made the export price of Việt Nam's broken rice drop to US$450 per tonne on June 19, the lowest level in the past two months.

Vietnam News Agency reported that domestic supply is increasing due to harvesting the summer-autumn rice crop. Việt Nam can export 2.3-2.5 million tonnes... (Read more)

## កសិករសាបព្រោះស្រូវនៅពេលយប់ ដើម្បីចៀសពីកំដៅថ្ងៃក្តៅខ្លាំង នៅទីក្រុងហាណូយ

វៀតណាម (Vietnam)

### (Farmers sow rice at night to avoid extreme heat in Hanoimonths)



*Vietnam Net: 24 June 2020*

Hordes of farmers in Thanh Oai district of Hanoi have to bring flashlights with them to sow rice at night instead of doing so in the daytime when temperatures can reach above 40 degrees Celsius. (Read more)

## ទីភ្នាក់ងារលទ្ធកម្មចំណីអាហារ នៅឥណ្ឌូនេស៊ី (Bulog) រំពឹងថានឹងមិនមានការនាំចូលអង្ករនេឆ្នាំនេះ

អាស៊ី (Asia)

### (Indonesia's Bulog expects no rice imports this year)

*Reuters: 26 June 2020*

BENGALURU, June 25 (Reuters) - Vietnamese rice export prices eased this week, hurt by falling purchases and quality concerns as the harvest progresses, while India rates rose from an over two-month low hit last week as demand picked up from Africa.

In Vietnam, rates for 5% broken rice RI-VNBKN5-P1 slipped to a range of $405-$450 per tonne on Thursday from $450 per tonne a week earlier. The winter-spring rice is offered at $450 per tonne, while the ongoing summer-autumn harvest is being offered at $405-$410 per.... (Read more)

## តើវៀតណាមកំពុងបោះជំហានឈានទៅមុខថៃ លើការនាំចេញអង្ករមែនទេ?

វៀតណាម (Vietnam)

### (Is Vietnam outstripping Thailand in rice exports?)



*Vietnam Net: 25 June 2020*

The US Department of Agriculture in its May report showed that Thailand suffers heavily from drought, while Vietnam doesn't. The agency predicted that Thailand's rice output this year would decrease by 2.34 million tons, or 11.5 percent, while Vietnam's output won't see reductions.

The reports of Thai agencies showed that the baht price increased by 2.18 percent in the first half of 2019,... (Read more)

## មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិហ្វីលីពីនបោះបង់ចោលផែនការនាំចូលអង្កររដ្ឋ និងរដ្ឋ (G2G)

ហ្វីលីពីន (Philipines)

### (PITC gives up rice G2G import plan)

*Manila Bulletin: 27 June 2020*

The Philippine International Trading Center (PITC), the government trading arm attached with the Department of Trade and Industry (DTI), is no longer proceeding with the planned government-to-government (G2G) importation of 300,000 metric ton (MT) of rice that was initially targeted to arrive during the lean months of July and August.

DTI Secretary Ramon M. Lopez said since there is no longer a threat to the food security of the country following Vietnam's lifting of its policy to impose a ban on rice exports, there is no need for PITC to pursue the planned rice importation. (Read more)

# ព្រឹត្តិការណ៍ និងសកម្មភាព
# (Event and Activity)






## កិច្ចប្រជុំស្តីពី ការចរចាកិច្ចសន្យាផលិតស្រូវសែនក្រអូប រវាងសហគមន៍កសិកម្មកំពង់ប្រាសាទ និងក្រុមហ៊ុន អេមរុរ៉ាយ (AMRU RICE) ក្រោមការសម្របសម្រួលពីសហព័ន្ធស្រូវអង្ករកម្ពុជា

នាថ្ងៃសៅរ៍ ៧កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ សហព័ន្ធស្រូវអង្ករកម្ពុជា បានចូលរួមសម្របសម្រួលក្នុងកិច្ចប្រជុំស្តីពី ការចរចា កិច្ចសន្យាកសិកម្ម រវាងសហគមន៍កសិកម្មកំពង់ប្រាសាទ ដែលជាសមាជិករបស់សហព័ន្ធស្រូវអង្ករកម្ពុជា ជាមួយនឹងក្រុមហ៊ុន អេមរុរ៉ាយ (AMRU RICE) នៅឯទីស្នាក់ការរបស់សហគមន៍កសិកម្មកំពង់ប្រាសាទ នៅភូមិកំពង់ប្រាសាទ ឃុំស្វាយអំពារ ស្រុកមុខកំពូល ខេត្តកណ្តាល។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងតបតាមការស្នើសុំពីសហគមន៍កសិកម្មកំពង់ប្រាសាទ ក្រោមការសម្របសម្រួលរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ដើម្បីឱ្យក្លាយជាវេទិកាជួបចរចាដោយបើកចំហ អំពីលទ្ធភាពក្នុងការឈានទៅរកការចុះកិច្ចសន្យាលើការផលិតស្រូវសែនក្រអូប ផ្គត់ផ្គង់ឱ្យក្រុមហ៊ុន អេមរុរ៉ាយ (AMRU RICE)។ កិច្ចប្រជុំនេះមានការចូលរួមពី សហព័ន្ធស្រូវអង្ករកម្ពុជា តំណាងដោយ លោក ខេ ឡុងម៉េង មន្ត្រីសម្របសម្រួលគណៈកម្មាធិការប្រតិបត្តិ និង តំបន់ ១ និង ២ របស់សហព័ន្ធស្រូវអង្ករកម្ពុជា ក្រុមហ៊ុន អេមរុរ៉ាយ (AMRU RICE) តំណាងដោយលោក កង យឿន បុគ្គលិកផ្នែកចុះកិច្ចសន្យាកសិកម្ម និងខាងសហគមន៍កសិកម្មកំពង់ប្រាសាទ តំណាងដោយ លោក សឿ សាខន ប្រធានសហគមន៍ រួមជាមួយនឹងបណ្តាកសិករដែលជាសមាជិក និងជាអ្នកផលិតស្រូវសែនក្រអូប។

ជាកិច្ចចាប់ផ្តើម លោក សឿ សាខន បានលើកឡើងត្រួសៗពីសាវតាររបស់សហគមន៍កសិកម្ម និងសក្តានុពល ក៏ដូចជាបទពិសោធន៍ជោគជ័យរបស់ សមាជិកក្នុងការផលិតស្រូវសែនក្រអូប នាឆ្នាំមុនៗកន្លងមក។ ក្នុងនោះ សហគមន៍កំពង់ប្រាសាទ បានចូលជាសមាជិកសហព័ន្ធស្រូវអង្ករកម្ពុជា នាដើមឆ្នាំ២០២០។ គិតមកទល់សព្វថ្ងៃនេះ សហគមន៍កំពង់ប្រាសាទ មានសមាជិកជាកសិករផលិតស្រូវសរុប ប្រមាណ ៤០០នាក់ជាង។



លោក កង យឿន តំណាងពីក្រុមហ៊ុនអេមរុរ៉ាយ បានលើកឡើងពីនីតិវិធី និងលក្ខខណ្ឌរបស់ក្រុមហ៊ុន ក្នុងការទិញស្រូវពីកសិករ ក៏ដូចជាសហគមន៍ ដែលមានដូចជា ក្រុមហ៊ុនមានផែនការប្រចាំឆ្នាំបែងចែកទៅតាមសហគមន៍ផ្សេងៗមុនពេលដាំដុះ រីឯលក្ខខណ្ឌផ្តោតលើការប្រើប្រាស់ជី និងថ្នាំ គឺគោរពតាមការណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការប្រើប្រាស់ពូជសុទ្ធ ជាដើម។ ក្នុងនោះ លោកក៏បានលើកឡើងអំពីការទូទាត់ ឆ្លើយតបទៅនឹងក្តីកង្វល់របស់កសិករ និងស្នើឱ្យកសិករមានការយោគយល់ក្នុងករណីយឺតយ៉ាវ ដើម្បីអាចរក្សាទំនាក់ទំនងកិច្ចសហការក្នុងរយៈពេលយូរអង្វែង។

លោក ខេ ឡុងម៉េង តំណាងឱ្យសហព័ន្ធស្រូវអង្ករកម្ពុជា បានលើកឡើងអំពីតួនាទីរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងការសម្របសម្រួល ឱ្យមានការជួបគ្នារវាងសហគមន៍ និងខាងក្រុមហ៊ុននាថ្ងៃនេះ ហើយសង្ឃឹមថាការចរចាទល់មុខគ្នានេះ នឹងផ្តល់នូវលទ្ធផលជាផ្លែផ្កា ក្នុងការធ្វើយ៉ាងណាផ្តល់ប្រយោជន៍ដល់កសិករដែលជាសមាជិក។



ជាលទ្ធផលនៃកិច្ចប្រជុំ ខាងសហគមន៍កសិកម្មកំពង់ប្រាសាទ ដោយមានការចូលរួមឯកភាពស្រុះស្រួលគ្នារបស់កសិករដែលជាសមាជិក បានស្នើទៅកាន់ក្រុមហ៊ុន ឱ្យទទួលទិញស្រូវសែនក្រអូបក្នុងតម្លៃថេរ (១១៤០រៀល/គីឡូក្រាម) និងក្នុងបរិមាណស្រូវដែលបានយល់ស្របព្រមព្រៀងជាមួយគ្នា។ តំណាងខាងក្រុមហ៊ុនអេមរុរ៉ាយ (AMRU RICE) នឹងយកលទ្ធផលពីការពិភាក្សាក្នុងកិច្ចប្រជុំរាយការណ៍ជូនទៅថ្នាក់លើ ដើម្បីទទួលបានការសម្រេចនាពេលបន្ទាប់ក្នុងពេលឆាប់ៗខាងមុខនេះ។

# សេចក្តីជូនដំណឹង
# (Announcement)

## ការហាមឃាត់ការប្រើប្រាស់ថ្នាំពុល កសិកម្ម នៅក្នុងទីផ្សារសហគមន៍អឺរ៉ុប
## (បច្ចុប្បន្នភាព ខែមិថុនា ឆ្នាំ២០២០)

ទាញយកឯកសារលម្អិត ៖ FERM Pesticide residue updated June 2020
(Click here to download)




## សហព័ន្ធស្រូវអង្ករកម្ពុជា (Cambodia Rice Federation)

**ប្រធានក្រុមប្រឹក្សាភិបាល (Chairman)**
លោកឧកញ៉ា ហ៊ុន ឡាក់ (Oknha Hun Lak)

**ប្រធានសហព័ន្ធ (President)**
លោកឧកញ៉ា សុង សារ៉ន (Okhna Song Saran)

**អគ្គលេខាធិការ (Secretary General)**
លោក លន់ យ៉េង (Mr. Lun Yeng)

**រៀបរៀង និងចងក្រងដោយ (Compiled by)**
កញ្ញា សន ឆវីតី - មន្រ្តីសម្របសម្រួលទំនាក់ទំនង
(Ms. Sorn Chhorvyvatey - Communication Coordinator)

**កែសម្រួលដោយ (Edited by)**
- លោក ខេ ឡុងម៉េង - មន្ត្រីសម្របសម្រួលគណៈកម្មាធិការប្រតិបត្តិ ស.អ.ក និងការងារប្រចាំតំបន់១&២ (Mr. Khe Longmeng - Executive Committees Coordinator and Zone 1&2 Coordinator)
- កញ្ញា ធុន ស្រីមុំ - ប្រធានរដ្ឋបាល និងហិរញ្ញវត្ថុ (Ms. Thun Sreymom - Admin and Finance Manager)

**រចនាដោយ (Designed by)**
កញ្ញា សន ឆវីតី - មន្រ្តីសម្របសម្រួលទំនាក់ទំនង
(Ms. Sorn Chhorvyvatey - Communication Coordinator)

## តម្លៃស្រូវ និងតម្លៃអង្ករនាំចេញ
## (Paddy price & FOB Price)




| Rice Varieties | Rice Standard (Price USD/ MT) 5% | 10% |
|---|---|---|
| Jasmine (Malys Angkor) | 910 | |
| Standard Fragrant Rice_SKO | 800 | |
| White Rice_Premium (Soft cooking) | 550 | |
| Parboiled Rice | 600 | |
| Organic Parboiled Rice | 1000 | |
| Organic Jasmine (Malys Angkor) | 1400 | |
| Organic Brown Jasmine (Premium Quality) | | 1370 |

**Source :** Cambodian Exporters and Millers
**Note:** Price Fluctuation : +/- 2%




| ខេត្ត | ស្រុក | ស្រូវសែនក្រអូប | ស្រូវអ៊ីអែរ | ស្រូវផ្សេងៗ |
|---|---|---|---|---|
| កំពង់ធំ | កំពង់ស្វាយ** | | *៨១០ | |
| បាត់ដំបង | បាណន់ *** | ១២៤០ | *៧៦០ | |
| ប៉ៃលិន | សាលាក្រៅ **** | | | ៩៥០ |
| កំពង់ឆ្នាំង | រលាប្អៀរ ***** | | | ៨៧០ |
| ព្រៃវែង | បាភ្នំ ***** | | *៨០០ | |


(855) 23 559 8999
info@crf.org.kh
Soma Tower, 7th Floor #2C, Street 120, Sangkat Phsar Thmey II, Khan Daun Penh, Phnom Penh, Cambodia
https://www.facebook.com/cambodiaricefederation/
www.crf.org.kh
https://twitter.com/RiceCrf
សហព័ន្ធស្រូវអង្ករកម្ពុជា Cambodia Rice Federation